# របាយការណ៍
# ស្តីពី
# លទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ខែមិថុនា ឆ្នាំ២០១០
# និង ទិសដៅការងារត្រួតពិនិត្យគ្រឿងញៀន ខែកក្កដា ឆ្នាំ២០១០

(០១/០៦/២០១០-៣០/០៦/២០១០)

អនុវត្តតាមផែនការសកម្មភាពជាតិឆ្នាំ២០១០ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងទិសដៅការងារដែលបានដាក់ចេញកាលពីខែឧសភាឆ្នាំ២០១០ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនបានបន្តកិច្ចសហការជាមួយក្រសួង-ស្ថាប័ន គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត អង្គការមិនមែនរដ្ឋាភិបាលជាតិ-អន្តរជាតិ និងវិស័យឯកជននានា អនុវត្តលើគ្រប់វិស័យក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន ទទួលបានលទ្ធផលល្អប្រសើរ ។

## I . សភាពការណ៍គ្រឿងញៀននៅកម្ពុជា

ក្នុងខែមិថុនានេះ តាមរយៈកិច្ចប្រតិបត្តិការបង្ក្រាបបទល្មើស បានបង្ហាញថា បទល្មើសគ្រឿងញៀនមានការកើនឡើង ហើយមេតំហ្វេតាមីនគ្រាប់ (WY) និង មេតំហ្វេតាមីន ICE នៅតែជាប្រភេទគ្រឿងញៀននាំមុខគេ ក្នុងការចរាចរចូលមកកម្ពុជា តាមច្រករបៀងនៃខេត្តស្ទឹងត្រែងជាមួយនឹងខេត្តចំប៉ាសាក់របស់ប្រទេសឡាវ ។ ក្រុមឈ្មួញគ្រឿងញៀនបានធ្វើការដឹកជញ្ជូនដោយថ្មើរជើងឆ្លងកាត់តំបន់ព្រៃស្មុគ្រស្មាញ ។ បន្ទាប់ពីនាំឆ្លងដែនចូលដល់ក្នុងប្រទេស គ្រឿងញៀនទាំងនោះ ត្រូវបានគេធ្វើចរាចរចែកចាយសំរាប់ការប្រើប្រាស់មួយចំនួន និង មួយចំនួនបាននាំទៅកាន់តំបន់ព្រំដែននៃប្រទេសជិតខាង ជាពិសេស តំបន់ព្រំដែននៃប្រទេសថៃ ។

ដោយមានកិច្ចសហការជាមួយមន្ទីរប្រឆាំងគ្រឿងញៀន រាជធានីភ្នំពេញ និងបណ្តាខេត្តមួយចំនួន ដូចជា ខេត្តបន្ទាយមានជ័យ ខេត្តប៉ៃលិន ខេត្តបាត់ដំបង ខេត្តកំពត ខេត្តព្រះសីហនុ ខេត្តកំពង់ចាម ខេត្តសៀមរាប ខេត្ត កណ្តាល ខេត្តស្ទឹងត្រែងបានធ្វើការបង្ក្រាបបទល្មើសគ្រឿងញៀននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនជាបន្តបន្ទាប់ ។ ក្នុងចំណោមករណីដែលបង្ក្រាបបានគឺមានពីរករណីធំ ហើយក្រៅពីនោះជាករណីតូចៗ ប៉ុន្តែកើតឡើងច្រើនកន្លែង ជាពិសេសគឺនៅរាជធានីភ្នំពេញ ។

## II . លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន :

### *ការងារដឹកនាំអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន*

ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តយកចិត្តទុកដាក់ចង្អុលដឹកនាំ

លើគ្រប់វិស័យក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន ជាអាទិ៍ :

-ការអញ្ជើញចុះទៅពិនិត្យនិងអនុម័តលើផែនការប្រតិបត្តិត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១០ របស់ខេត្តបន្ទាយមានជ័យ(០១-០៣/៦/២០១០) ដែលក្នុងនោះមានតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធលើគ្រប់វិស័យ ព្រមទាំងរាជធានីភ្នំពេញ ខេត្តបាត់ដំបង ខេត្តសៀមរាប ខេត្តកំពង់ចាម ខេត្តកណ្ដាល ខេត្ត ព្រះសីហនុ ខេត្តស្ទឹងត្រែង ខេត្តប៉ៃលិន បានទៅចូលរួមស្ដាប់ការណែនាំអនុវត្តផែនការប្រតិបត្តិនេះ ។

-ការអញ្ជើញចុះទៅសំណេះសំណាលជាមួយលោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស នៅវិទ្យាល័យឥន្ទ្រទេវី(១៩/៦/២០១០)ដើម្បីក្ដាប់ពីសភាពការណ៍រួមរបស់សាលា និងអប់រំពីគ្រោះថ្នាក់ដែលបណ្ដាលមកពីការប្រើបំពានគ្រឿងញៀន ។

-ការដឹកនាំប្រារព្ធទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ថ្ងៃទី២៦ មិថុនា ២០១០ នៅខេត្តបន្ទាយមានជ័យ ។

## ***១-ការកាត់បន្ថយតម្រូវការគ្រឿងញៀន :***

ចំពោះការកាត់បន្ថយតម្រូវការគ្រឿងញៀន អាជ្ញាធរជាតិបានយកចិត្តទុកដាក់លើការងារផ្សព្វផ្សាយអប់រំ ដើម្បីលើកកំពស់ការយល់ដឹងជាសាធារណៈ ជាអាទិ៍ :

ការរៀបចំទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ២៦មិថុនា២០១០ ក្រោមប្រធានបទដែលកំណត់ដោយការិយាល័យគ្រឿងញៀននិងឧក្រិដ្ឋកម្មគឺ **ដើម្បីសុខភាព ត្រូវបដិសេធគ្រឿងញៀន** ។ ដោយឡែកប្រធានបទ ដែលលើកឡើងដោយអាជ្ញាធរជាតិគឺមានពីរខ្លឹមសារ **មានឬគ្មានគ្រឿងញៀន យើងជាអ្នកកំណត់** និង **គ្រប់យ៉ាងដើម្បីសហគមន៍គ្មានគ្រឿងញៀន** ។ ទិវាឆ្នាំនេះ យើងបានគោរពស្នើសុំសម្ដេចផ្ញើសារលិខិតទៅកាន់បងប្អូនជនរួមជាតិ និងបានផ្ញើសារលិខិតនេះទៅតាមរាជធានី-ខេត្តដើម្បីអាននៅក្នុងថ្ងៃប្រារព្ធទិវាទូទាំងប្រទេស ។ សំរាប់ខេត្តបន្ទាយមានជ័យ អាជ្ញាធរជាតិបានរៀបចំទិវានេះ នៅក្រុងសិរីសោភ័ណនៅថ្ងៃទី២៦មិថុនា២០១០ ក្រុងប៉ោយប៉ែត នៅថ្ងៃទី២៧មិថុនា២០១០ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **កែ គឹមយ៉ាន** ដែលមានមហា ជនចូលរួមប្រមាណ ៦.៨៨១ នាក់។ នៅស្រុកមង្គលបុរី និង ស្រុកថ្មពួក ទិវានេះយើងបានប្រគល់ឱ្យខេត្តជាអ្នករៀបចំ ហើយនៅថ្ងៃទី២៨មិថុនា២០១០ ខេត្តត្រូវណែនាំឱ្យស្រុកដទៃទៀតរៀបចំទិវានេះ នៅតាមបណ្ដាឃុំគោលដៅសំខាន់ៗ ។

ជាមួយនេះ តាមសំណើរបស់ស្ថានីយ៍ទូរទស្សន៍ជាតិកម្ពុជា(ទទក) និង អគ្គនាយដ្ឋានវិទ្យុជាតិកម្ពុជា អគ្គលេខាធិការដ្ឋានអជបគញ បានផ្ដល់កិច្ចសម្ភាសន៍ក្រោមប្រធានបទស្ដីពី **"គ្រឿងញៀននៅកម្ពុជា"** និងចូលរួមជាវាគ្មិននៅក្នុងកម្មវិធីសន្ទនាមតិ **"ជីវិតយើង សង្គមយើង"** ក្រោមប្រធានបទ **"យុវជននិងគ្រឿងញៀន"** ដើម្បីចាក់ផ្សាយក្នុងកម្មវិធី**អរុណសួស្ដីកម្ពុជា** ក្នុងគោលបំណងចូលរួមអបអរសាទរទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ២៦ មិថុនា ២០១០។

តាមកម្មវិធីដែលផ្ដល់ដោយស្ថានីយ៍ទូរទស្សន៍CTNរៀងរាល់មួយខែម្ដង ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និង យុវនីតិសម្បទាក៏បានផ្ដល់កិច្ចសម្ភាសន៍ក្រោមប្រធានបទស្ដីពី ការទទួលខុសត្រូវរបស់ក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទា ក្នុងការបង្ការការព្យាបាល និងស្ដារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។

ក្រសួងឧស្សាហកម្មរ៉ែនិងថាមពល បានធ្វើការណែនាំដល់ម្ចាស់រោងចក្រ-សិប្បកម្មផលិតទឹកពិសាជប នៅតាមរាជធានី-ខេត្ត

ឱ្យចូលរួមធ្វើការបោះពុម្ពនិងបិទផ្សាយលើដបទឹកពិសាររបស់ខ្លួនអំពី**សារ**អប់រំពីគ្រោះថ្នាក់ ដែលបណ្តាលមកពីការប្រើប្រាស់គ្រឿងញៀន ដែលមានបីខ្លឹមសារសំរាប់ជ្រើសរើសគឺ **ការប្រើប្រាស់គ្រឿងញៀនជាអំពើខុសនឹងច្បាប់ , គ្រឿងញៀនបំផ្លាញ អនាគតអ្នក និងសង្គម , គ្រឿងញៀនគឺជាអ្នកបំផ្លាញអាយុជីវិត និងទ្រព្យសម្បត្តិរបស់អ្នក** ។

ដោយឡែក បណ្តាខេត្ត និង សមាគមមួយចំនួន ក៏បានបន្តការយកចិត្តទុកដាក់ចូលរួមលើការងារផ្សព្វផ្សាយអប់រំពីគ្រោះថ្នាក់នៃគ្រឿងញៀន សរុបបានចំនួន **១២.២៣០** នាក់ ក្នុងនោះរួមមាន ÷

| **អង្គភាព** | **ខ្លឹមសារ** | **សមាសភាព** | **ចំនួន** |
|---|---|---|---|
| នគរបាល ខេត្តបាត់ដំបង | គ្រោះថ្នាក់នៃគ្រឿងញៀន | ប្រជាពលរដ្ឋ | ៦០៩ នាក់ |
| ខេត្តកណ្តាល | គ្រោះថ្នាក់នៃគ្រឿងញៀន | ប្រជាពលរដ្ឋទូទៅ និង ក្រុមជនងាយទទួលរងគ្រោះ | ១.២៨៣ នាក់ |
| នគរបាល ខេត្តកំពង់ចាម | ច្បាប់ និង គ្រោះថ្នាក់នៃគ្រឿងញៀន | មន្ត្រីរាជការ មន្ត្រីអនុវត្តច្បាប់ សិស្ស ពលរដ្ឋ សណ្ឋាគារនិងកន្លែងសប្បាយ | ១៤៩៨ នាក់ |
| នគរបាល ខេត្តពោធិសាត់ | ច្បាប់ និង កិច្ចសន្យារដ្ឋបាល | សណ្ឋាគារ ផ្ទះសំណាក់ ខារ៉ាអូខេ | ៤៥ នាក់ |
| នគរបាល ខេត្តកំពង់ធំ | គ្រោះថ្នាក់នៃគ្រឿងញៀន | ប្រជាពលរដ្ឋ សិស្សានុសិស្ស | ៣.៤១៣ នាក់ |
| នគរបាលខេត្តកំពង់ស្ពឺ | គ្រោះថ្នាក់នៃគ្រឿងញៀន | ប្រជាពលរដ្ឋ សិស្សានុសិស្ស | ២.៦៣៥ នាក់ |
| នគរបាលខេត្តក្រចេះ | គ្រោះថ្នាក់នៃគ្រឿងញៀន | ប្រជាពលរដ្ឋ សិស្សានុសិស្ស | ៧៣៣ នាក់ |
| ក្រុមប្រឹក្សាឃុំជាំក្សាន្ត ព្រះវិហារ | គ្រោះថ្នាក់នៃគ្រឿងញៀន | ប្រជាពលរដ្ឋ | ៥០ នាក់ |
| គណៈកម្មាធិការ គ.ញ ម.គីរី | គ្រោះថ្នាក់នៃគ្រឿងញៀន | ប្រជាពលរដ្ឋ សិស្សានុសិស្ស | ៣៦៥ នាក់ |
| នគរបាលខេត្តមណ្ឌលគីរី | គ្រោះថ្នាក់នៃគ្រឿងញៀន | អ្នកបំរើសេវាកំសាន្ត | ១៦ នាក់ |
| បណ្តាញសមាគមយុវជនខ្មែរនៅប៉ៃលិន | គ្រោះថ្នាក់នៃគ្រឿងញៀន | យុវជនតាមទីសាធារណៈ ស្ត្រីបំរើសេវាកំសាន្ត | ៣៥២ នាក់ |
| សមាគមនារី ខេត្តប៉ៃលិន | គ្រោះថ្នាក់នៃគ្រឿងញៀន | ស្ត្រីបំរើសេវាកំសាន្ត | ៤៤៥ |
| នគរបាល ខេត្តកំពង់ឆ្នាំង | បិទសេចក្តីជូនដំណឹងហាមឃាត់ជួញដូរ ប្រើប្រាស់តាមទីសាធារណៈ និង តាមសាលារៀន ចំនួន ១២២ សន្លឹក | | |
| នគរបាលខេត្តតាកែវ | បិទសេចក្តីជូនដំណឹងហាមឃាត់ជួញដូរ ប្រើប្រាស់តាមទីសាធារណៈ និង តាមសាលារៀន ចំនួន ១៧ សន្លឹក | | |
| នគរបាលខេត្តកំពត | បិទសេចក្តីជូនដំណឹងហាមឃាត់ជួញដូរ ប្រើប្រាស់តាមទីសាធារណៈ និងធ្វើកិច្ចសន្យារដ្ឋបាល ១២១ កន្លែង | | |
| នគរបាលខេត្តកែប | បញ្ជ្រាបកម្មវិធីអប់រំពីគ្រឿងញៀនទៅក្នុងទិវាពិភពលោកប្រឆាំងពលកម្មកុមារ និង ក្នុងទិវាកុមារអន្តរជាតិ | | ៦៥៦ នាក់ |
| ក្រុមប្រឹក្សាយុវជនកម្ពុជាប្រចាំខេត្តកំពង | ដង្ហែក្បួនប្រឆាំងគ្រឿងញៀន | | ៨៦ នាក់ |
| **សរុប** | | | **១២.២៣០ នាក់** |

ថ្មីៗនេះ អាជ្ញាធរជាតិបានគាំទ្រលើគំរោងសាកល្បងស្តីពី គ្មានការប្រើប្រាស់គ្រឿងញៀននៅក្នុងសាលារៀន និង ការផ្តល់សេវាកម្មគាំទ្រផ្អែកលើមូលដ្ឋានសហគមន៍នៅកម្ពុជា របស់អង្គការ Muslim Aid ។ តាមរយៈគំរោងនេះ អាជ្ញាធរជាតិបានស្នើសុំឱ្យអង្គការ Muslim Aid ពង្រីកគោលដៅអនុវត្តគំរោងរបស់ខ្លួនទៅកាន់ខេត្តបន្ទាយមានជ័យបន្ថែមទៀត ដោយត្រូវធ្វើកិច្ចសហការល្អជាមួយអាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់និងស្ថាប័នពាក់ព័ន្ធនានា ។

## ***២_ការកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន :***

### ***២.១-ការងារបង្ក្រាបបទល្មើសគ្រឿងញៀន***

ខែមិថុនាឆ្នាំ២០១០ បង្ក្រាបបទល្មើសបាន **៣៨ ករណី** ឃាត់ខ្លួនជនល្មើសចំនួន **៨៣** នាក់( ប្រុស ៥៦ នាក់ ស្រី ២៧នាក់) បញ្ជូនទៅតុលាការ ក្នុងនោះមាន ជនជាតិខ្មែរ **៧៥** នាក់ ( ប្រុស **៤៩** នាក់ ស្រី **២៦**នាក់) វៀតណាម **៧** នាក់

( ប្រុស **៦** នាក់ ស្រី **១** នាក់) ហ្វាំងឡង់ **១** នាក់( ប្រុស) ។

**វត្ថុតាងចាប់យក** មេតំហ្វេតាមីន **WY ៤.៦១៩** គ្រាប់, ម្សៅមេតំហ្វេតាមីន **ICE** ១៦១,៥៥ ក្រាម, ហេរ៉ូអ៊ីន **១,៥០** ក្រាម, អ៊ិចស្តាស៊ី ១៤០ គ្រាប់, ម្សៅពណ៌ស ០,៥ ក្រាម, ម្សៅពណ៌ទឹកដោះគោ ៣,០៨ ក្រាម, ជញ្ជីង ៣, ម៉ូតូ ៩ គ្រឿង, អាវុធវែង ១ ដើម, ឧបករណ៍ប្រើប្រាស់គ្រឿងញៀនមួយចំនួន ។

**អង្គភាពប្រតិបត្តិការបង្ក្រាបបទល្មើស រួមមាន :**

| ល.រ | អង្គភាពបង្ក្រាប | សរុបរួម | | | ចរាចរជួញដូរចែកចាយ | | | ប្រើប្រាស់គ្រឿងញៀន | | | ចាប់តាមដីកា | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ករណី | សរុប | ស្រី | ករណី | សរុប | ស្រី | ករណី | សរុប | ស្រី | ករណី | សរុប | ស្រី |
| ១ | មន្ទីរប្រឆាំងគ្រឿងញៀន | **១០** | **២០** | **៦** | ១០ | ១៩ | ៦ | | | | ០ | ១ | ០ |
| ២ | រាជធានីភ្នំពេញ | **៦** | **១០** | **៥** | ៦ | ១០ | ៥ | | | | | | |
| ៣ | កណ្តាល | **៣** | **៩** | **០** | ១ | ១ | ០ | ២ | ៨ | ០ | | | |
| ៤ | កំពង់ចាម | **១** | **១** | **០** | ១ | ១ | ០ | | | | | | |
| ៥ | ព្រះសីហនុ | **៥** | **១៩** | **៨** | ៣ | ៨ | ៣ | ២ | ១០ | ៥ | ០ | ១ | ០ |
| ៦ | សៀមរាប | **១** | **១** | **០** | ១ | ១ | ០ | | | | | | |
| ៧ | ស្ទឹងត្រែង | **១** | **១** | **០** | ១ | ១ | ០ | | | | | | |
| ៨ | កំពត | **១** | **១** | **១** | ១ | ១ | ១ | | | | | | |
| ៩ | បាត់ដំបង | **៦** | **១០** | **១** | ៥ | ៨ | ១ | ១ | ១ | ០ | ០ | ១ | ០ |
| ១០ | បន្ទាយមានជ័យ | **៣** | **១០** | **៥** | ៣ | ៨ | ៤ | | | | ០ | ២ | ១ |
| ១១ | ប៉ៃលិន | **១** | **១** | **១** | | | | ១ | ១ | ១ | | | |
| **សរុប** | | **៣៨** | **៨៣** | **២៧** | **៣២** | ៥៨ | ២០ | **៦** | ២០ | ៦ | **០** | ៥ | ១ |

## ***២.២-ទិន្នន័យសារធាតុគីមីផ្សំ***

អគ្គលេខាធិការដ្ឋាន បានសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ធ្វើការប្រមូលទិន្នន័យសារធាតុគីមីផ្សំ ដែលមានអាជ្ញាប័ណ្ណនាំចូលប្រចាំខែមិថុនាឆ្នាំ២០១០ សរុបមានចំនួន **1.543.168 Kgs** និង **144 L** ( មានតារាងឧបសម្ព័ន្ធជូនភ្ជាប់ជាមួយរបាយការណ៍) ។

## ***៣-ការព្យាបាលស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន និង ការកាត់បន្ថយគ្រោះថ្នាក់ដែលបណ្តាលមកពីគ្រឿងញៀន :***

**ចំពោះការព្យាបាលស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន** យើងបានបញ្ជូនសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការបង្កើតមជ្ឈមណ្ឌលជាតិព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ជាមួយនូវសេចក្តីថ្លែងហេតុ បញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីត្រៀមដាក់ជូនសម័យប្រជុំ ពេញអង្គគណៈរដ្ឋមន្ត្រីពិនិត្យនិងសំរេច ។

ដោយឡែក ក្រសួងសុខាភិបាល យោងចំណារឯកភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១៣ខែឧសភាឆ្នាំ២០១០ លើរបាយការណ៍និងសំណើរបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំង

គ្រឿងញៀន បានស្នើសុំឱ្យក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ចាត់បញ្ជូនលិខិតស្នើសុំរបស់ខ្លួន ទៅកាន់ក្រសួងសុខាភិបាល នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ដើម្បីស្នើសុំឱសថសំរាប់ព្យាបាលអ្នកញៀនគ្រឿងញៀន ឈ្មោះ បុងសែន (Bong Sen) ។

**ការកាត់បន្ថយគ្រោះថ្នាក់ដែលបណ្តាលមកពីគ្រឿងញៀន** អគ្គលេខាធិការ អជបគញ តាមការអញ្ជើញ របស់អង្គការ AUSAID បានចូលរួមធ្វើជាសហប្រធាននៃកិច្ចប្រជុំលើកទី២ របស់គណៈកម្មាធិការដឹកនាំគំរោងកម្មវិធី អេដស៍ប្រចាំតំបន់អាស៊ី (HAARP) កាលពីថ្ងៃទី០៩ខែមិថុនាឆ្នាំ២០១០ នៅសាលប្រជុំរបស់អគ្គលេខាធិការដ្ឋាន ។

### *៤. ការពង្រឹងសមត្ថភាពអនុវត្តច្បាប់*

ការងារនេះ អាជ្ញាធរជាតិបានពង្រីកកិច្ចសហប្រតិបត្តិការជាមួយ អគ្គរដ្ឋអាជ្ញានៃសាធារណរដ្ឋកូរ៉េ សំរាប់ការត្រួតពិនិត្យគ្រឿងញៀននៅកម្ពុជា ។ តាមរយៈគំរោងនេះ អាជ្ញាធរជាតិបានបញ្ជូនមន្ត្រីអនុវត្តច្បាប់ ទៅធ្វើការបណ្តុះបណ្តាលនៅសាធារណរដ្ឋកូរ៉េលើជំនាញត្រួតពិនិត្យគ្រឿងញៀន ការវិភាគគ្រឿងញៀន និង ការពង្រឹងសមត្ថភាពមន្ទីរពិសោធន៍គ្រឿងញៀន ពីខែកក្កដា ដល់ ខែសីហា ខាងមុខនេះ ។

តបតាមសំណើរបស់ អគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរណ៍-អាហរណ៍និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល) អគ្គលេខាធិការដ្ឋាន អជបគញ បានចាត់គ្រូឧទ្ទេសនាមចំនួន ២ រូប ទៅធ្វើការបណ្តុះបណ្តាលដល់មន្ត្រីកាំកុងត្រូលអំពីការត្រួតពិនិត្យសារធាតុគីមីផ្សំ ដើម្បីមានមូលដ្ឋានគ្រឹះក្នុងការត្រួតពិនិត្យគ្រឿងញៀន នៅអគ្គនាយកដ្ឋានកាំកុងត្រូលរយៈពេល១សប្តាហ៍ ពីថ្ងៃទី២១-២៥ខែមិថុនាឆ្នាំ២០១០ ។

ដោយឡែក មន្ទីរប្រឆាំងគ្រឿងញៀននៃក្រសួងមហាផ្ទៃ បានចាត់បញ្ជូននាយនគរបាលចំនួន ៥ រូប ទៅចូលរួមវគ្គសិក្សាក្នុងកម្មវិធីអន្តរជាតិសំរាប់មន្ត្រីផ្នែកចារកម្ម ដែលមានរយៈពេលពីរសប្តាហ៍នៅសណ្ឋាគារណាហ្គាវើល (ពីថ្ងៃទី០៧-១៧ ខែមិថុនា ឆ្នាំ២០១០) ។

### *៥. កិច្ចសហប្រតិបត្តិការអន្តរជាតិ :*

ការងារនេះ អាជ្ញាធរជាតិបានចាត់មន្ត្រីសម្របសម្រួលគំរោងចំនួន ២ រូប ទៅចូលរួមក្នុងកិច្ចប្រជុំប្រចាំឆ្នាំថ្នាក់មន្ត្រីជាន់ខ្ពស់នៃបណ្តាប្រទេសសមាជិកអនុស្សារណៈនៃការយោគយល់គ្នាឆ្នាំ១៩៩៣ នៅទីក្រុងដាណាង នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ។ កិច្ចប្រជុំបានពិភាក្សាយ៉ាងផុលផុសពាក់ព័ន្ធនឹងការអនុវត្តន៍ផែនការសកម្មភាពអនុតំបន់(SAP) ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។ បញ្ហាដែលបានឯកភាពគ្នារួមមាន ការបន្តគំរោងH15ស្តីពីការធ្វើឱ្យកាន់តែមានភាពប្រសើរឡើងនៃបណ្តាប្រទេសសមាជិកអនុស្សារណៈនៃការយោគយល់គ្នាឆ្នាំ១៩៩៣, ការស្នើសុំឱ្យUNODC បង្កើនទូវថវិកាបដិភាគយ៉ាងហោច៥០%នៃថវិកាសរុបដែលទទួលបានពីប្រទេសសមាជិក, ការស្នើសុំឱ្យUNODC បង្ហាញពីតារាងចំណាយលំអិតលើសកម្មភាពដែលបានអនុវត្តក្នុងឆ្នាំ២០០៨ និង ២០០៩, ការរៀបចំសន្និសីទថ្នាក់រដ្ឋមន្ត្រីជាមួយប្រទេសផ្តល់ជំនួយសំរាប់គាំទ្រផែនការអនុតំបន់ និងការត្រៀមរៀបចំកិច្ចប្រជុំនេះ សំរាប់ឆ្នាំ២០១១នៅប្រទេសឡាវ ។

ក្រៅពីនោះ អាជ្ញាធរជាតិបានចាត់បញ្ជូនមន្ត្រីជំនាញទៅចូលរួមវេទិកាពិគ្រោះយោបល់និងសម្របសម្រួលគំរោងកម្មវិធីអេដស៍ប្រចាំតំបន់អាស៊ី (HAARP) នៅសាធារណរដ្ឋសង្គមនិយមវៀតណាមកាលពីថ្ងៃទី២២-២៤ ខែមិថុនា ឆ្នាំ២០១០ ។

បានចាត់មន្ត្រីជំនាញទៅចូលរួមសិក្ខាសាលា ស្តីពីកិច្ចសហប្រតិបត្តិការអនុវត្តគំរោងត្រួតពិនិត្យគ្រឿងញៀន នៅកោះបាលី ប្រទេសឥណ្ឌូនេស៊ី (២៨-២៩/៦/២០១០) ដែលគំរោងនេះគឺជាគំរោងក្នុងក្របខណ្ឌអាស៊ាន បូក កូរ៉េ ។

## III . ការសន្និដ្ឋាន និង វាយតម្លៃ :

ជារួម ក្នុងខែមិថុនានេះ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនបានបន្តយកចិត្តទុកដាក់អនុវត្តនូវវិធានការពហុវិស័យក្នុងការត្រួតពិនិត្យគ្រឿងញៀនទទួលបានលទ្ធផលគួរកត់សំគាល់ ។

**លើការងារផ្សព្វផ្សាយអប់រំ** លើកកំពស់ការយល់ដឹងជាសាធារណៈអំពីច្បាប់និងគ្រោះថ្នាក់នៃគ្រឿងញៀន យើងបានយកចិត្តទុកដាក់សហការសម្របសម្រួលជាមួយក្រសួង-ស្ថាប័នរដ្ឋ គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត អង្គការមិនមែនរដ្ឋាភិបាលជាតិ-អន្តរជាតិ និងវិស័យឯកជន ចលនាឱ្យមានការចូលរួមយ៉ាងសកម្មផុលផុសលើការងារនេះ ។ ទន្ទឹមនេះ អាជ្ញាធរជាតិបានចូលរួមប្រារព្ធទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដោយបានធ្វើការផ្លាស់ប្តូររបៀបប្រមូលផ្តុំមីទ្ទិញសំដៅធ្វើឱ្យការអប់រំផ្សព្វផ្សាយតាមរយៈទិវានេះ បានចូលជ្រៅទៅដល់ប្រជាពលរដ្ឋនៅតាមសហគមន៍ជនបទ ។ ប៉ុន្តែទោះ បីជាយើងបានខិតខំលើការងារនេះទទួលបានជោគជ័យ ច្រើនជាងឆ្នាំមុនក៏ពិតមែន តែក៏នៅមានបញ្ហាប្រឈមមួយចំនួនផងដែរ ជាអាទិ៍ យើងនៅមិនទាន់បានផលិតឯកសារ ឬ សារ សំរាប់ចាក់អប់រំ និង បិទអប់រំ ឱ្យបានសម្បូរបែបប្រកបទៅដោយខ្លឹមសារស៊ីជម្រៅ ដើម្បីទាញការចាប់អារម្មណ៍ពីក្រុមជនដែលងាយទទួលរងគ្រោះ ។ ជាមួយនេះ ចំពោះការបិទផ្សាយ ឧទាហរណ៍ ការបិទផ្សាយនៅផ្ទះសំណាក់ ឬសណ្ឋាគារ និងកន្លែងសប្បាយនានា យើងនៅមិនទាន់បានផលិតជាឯកសារដែលមានខ្លឹមសាររួមបញ្ចូលគ្នា ដើម្បីឱ្យម្ចាស់ទីតាំងអាចងាយស្រួលនឹងសហការជាមួយសមត្ថកិច្ចយើង ។

**លើការងារកាត់បន្ថយតម្រូវការគ្រឿងញៀន** យើងបានយកចិត្តទុកដាក់បង្ក្រាបបទល្មើសទទួលបានលទ្ធផលច្រើន រួមទាំងករណី តូច មធ្យម ធំ ប៉ុន្តែបញ្ហាប្រឈមគឺ យើងនៅមានការខ្វះខាតនូវសម្ភារៈ បច្ចេកទេសមន្ទីរពិសោធន៍គ្រឿងញៀន សមត្ថភាពនិងធនធានមនុស្សនៅមានកំរិត ។ យើងមិនទាន់មានមន្ទីរ ពិសោធន៍គ្រឿងញៀនខ្នាតតូចសំរាប់បំពាក់ឱ្យភូមិភាគដែលនៅឆ្ងាយដើម្បីមានលទ្ធភាពធ្វើការវិភាគលើសំណាកវត្ថុតាងបានទាន់ពេលវេលាតាមនីតិវិធីតុលាការ ។ ការរៀបចំច្បាប់ថ្មីស្តីពីការត្រួតពិនិត្យគ្រឿងញៀននៅមានភាពយឺតយ៉ាវ ។ នៅថ្នាក់ក្រោមជាតិ សមត្ថភាពមន្ត្រីអនុវត្តច្បាប់នៅមូលដ្ឋាននៅមានកំរិតនៅឡើយ ។ ជាមួយនេះ ការចុះធ្វើកិច្ចសន្យារដ្ឋបាលនៅតាមផ្ទះសំណាក់ សណ្ឋាគារ និង កន្លែងសប្បាយនានានៅមិនទាន់អនុវត្តឱ្យបានហ្មឹងម៉ាត់ មូលដ្ឋានខ្លះមិនបានយកចិត្តទុកដាក់អនុវត្ត ជាហេតុធ្វើឱ្យពួកឈ្មួញគ្រឿងញៀន ក៏ដូចអ្នកប្រើប្រាស់គ្រឿង ញៀន នៅតែឆ្លៀតយកទីនោះធ្វើជាកន្លែងជួញដូរ ចែកចាយ និង ប្រើប្រាស់គ្រឿងញៀនបាន ។

**ចំពោះការងារព្យាបាលនិងស្តារនីតិសម្បទា** យើងសំរេចបាននូវអនុក្រឹត្យស្តីពីការបង្កើតមជ្ឈមណ្ឌលជាតិព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន និងបានបញ្ជូនសេចក្តីព្រាងនេះទៅទីស្តីការគណៈរដ្ឋមន្ត្រី ។

ដោយឡែក ទីតាំងដែលត្រូវសាងសង់មជ្ឈមណ្ឌល យើងកំពុងជំរុញឱ្យភាគីវៀតណាមផ្តល់នូវជំនួយសំរាប់ការសាងសង់អាគារមជ្ឈមណ្ឌលឱ្យបានឆាប់ ។ យើងក៏បានផ្តល់នូវមណ្ឌលសុខភាពមួយខ្នងដល់មណ្ឌល **ពិភពនៃក្តីសង្ឃឹម** នៅស្រុកបវេល ខេត្តបាត់ដំបង តែយើងនៅខ្វះខាតសម្ភារៈ និង ថ្នាំពេទ្យ ព្រមទាំងគ្រូពេទ្យដែលបំរើការងារនៅក្នុងមណ្ឌល ។ ចំពោះ

មុខអាជ្ញាធរជាតិត្រូវសម្របសម្រួលជាមួយក្រសួងសុខាភិបាល ដើម្បីបង្កើតបទដ្ឋានគំរូឯកភាព សំរាប់ផ្តល់សេវាថែទាំសុខភាពអ្នករងគ្រោះដោយសារគ្រឿងញៀន និងការរៀបចំឱ្យមានជំពូកចំណាយដោយថវិកាជាតិសំរាប់ទិញឱសថព្យាបាលអ្នកញៀនគ្រឿងញៀន ។

## IV. ទិសដៅការងារត្រួតពិនិត្យគ្រឿងញៀន ខែកក្កដា ឆ្នាំ២០១០ :

ដូចបានធ្វើការសន្និដ្ឋាន និង វាយតម្លៃអំពីសភាពការណ៍គ្រឿងញៀន និងចំណុចប្រឈមក្នុងការអនុវត្តនូវយុទ្ធសាស្ត្រខាងលើ អាជ្ញាធរជាតិបានដាក់ចេញនូវទិសដៅដើម្បីអនុវត្តបន្តដូចតទៅ :

### ១_ការងារកាត់បន្ថយតម្រូវការគ្រឿងញៀន :

-បន្តកិច្ចសហការ សម្របសម្រួល ជាមួយក្រសួងពាក់ព័ន្ធ ក្នុងនោះរួមមាន ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍, ក្រសួងអប់រំយុវជននិងកីឡា, ក្រសួងឧស្សាហកម្មរ៉ែនិងថាមពល, ក្រសួងពាណិជ្ជកម្ម, ក្រសួងទេសចរណ៍, ក្រសួងសាធារណការនិងដឹកជញ្ជូន, ក្រសួងព័ត៌មាន, ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ដើម្បីជំរុញការចាក់ផ្សាយ សារ និងបិទសារអប់រំពីគ្រោះថ្នាក់នៃគ្រឿងញៀន ។

-បន្តសហការ សម្របសម្រួល ជាមួយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត និងបំផុសលើកទឹកចិត្តដល់អង្គការមិនមែនរដ្ឋាភិបាលជាតិ-អន្តរជាតិ និង វិស័យឯកជន ឱ្យបន្តចូលរួមក្នុងការផ្សព្វផ្សាយអប់រំលើកកំពស់ការយល់ដឹងពីគ្រឿងញៀន ។

-បន្តសហការជាមួយស្ថានីយ៍ទូរទស្សន៍រដ្ឋនិងឯកជន អង្គការមិនមែនរដ្ឋាភិបាល ក្នុងការផ្តល់បទសម្ភាសន៍ ស្តីពីបញ្ហាគ្រឿងញៀននៅកម្ពុជា, គ្រោះថ្នាក់នៃគ្រឿងញៀន និង ការទទួលខុសត្រូវរបស់ក្រសួងសមាជិកអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

-បន្តការរៀបចំទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ២៦មិថុនា២០១០ នៅខណ្ឌទួលគោក ថ្ងៃទី០៩ខែកក្កដា ឆ្នាំ២០១០ ។

-ធ្វើការបូកសរុបវាយតម្លៃ អំពីការប្រារព្ធទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ២៦មិថុនា២០១០ ។

### ២_ការងារព្យាបាល ស្តារនីតិសម្បទា និង សមាហរណកម្ម
### និង ការកាត់បន្ថយគ្រោះថ្នាក់ដែលបណ្តាលមកពីការប្រើប្រាស់គ្រឿងញៀន

-បន្តសម្របសម្រួលជាមួយភាគីវៀតណាម ដើម្បីផ្តល់ជំនួយសំរាប់សាងសង់មជ្ឈមណ្ឌលជាតិព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។

-បន្តការរៀបចំសេចក្តីព្រាងគោលនយោបាយជាតិ ស្តីពីការព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន និងការរៀបចំសេចក្តីព្រាងស្តីពីតំរូវការអប្បបរមាក្នុងការព្យាបាល និងស្តារនីតិសម្បទាអ្នកញៀន គ្រឿងញៀន ។

-បន្តជំរុញការតម្លើងបញ្ជីឈ្មោះ ឃុំ-សង្កាត់អាទិភាព សំរាប់ធ្វើសកម្មភាពត្រួតពិនិត្យគ្រឿងញៀននៅឆ្នាំ២០១០,

ឈ្មោះនិងទីតាំងមណ្ឌលសុខភាព, ឈ្មោះទីតាំងនិងវិសាលភាពនៃការអនុវត្តន៏ការងាររបស់អង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើការងារពាក់ព័ន្ធនឹងគ្រឿងញៀន និងជម្ងឺអេដស៍នៅរាជធានី-ខេត្ត ។

-សហការនិងសម្របសម្រួលជាមួយក្រសួងសុខាភិបាល ដើម្បីពង្រឹងសមត្ថភាពមណ្ឌលបណ្តោះអាសន្នសំរាប់អប់រំ បន្សាប និង ព្យាបាលអ្នកញៀនគ្រឿងញៀនដែលមានស្រាប់ រួមទាំងការរៀបចំជំពូកចំណាយដោយថវិកាជាតិ សំរាប់ទិញឱសថព្យាបាលអ្នកញៀនគ្រឿងញៀន ។

-ត្រៀមចាត់បញ្ជូនមន្ត្រីមួយរូប តាមសំណើរបស់អង្គការសម្ព័ន្ធភាពខ្មែរប្រឆាំងនឹងជម្ងឺអេដស៍(KHANA)ទៅចូលរួមធ្វើទស្សនកិច្ចសិក្សាកម្មវិធីកាត់បន្ថយគ្រោះថ្នាក់(Harm Reduction)នៅប្រទេសម៉ាឡេស៊ី (ថ្ងៃទី០៥-០៨ កក្កដា ២០១០) ។

## ៣_ការពង្រឹងសមត្ថភាពអនុវត្តច្បាប់

-បន្តកិច្ចសហការ និង សម្របសម្រួលជាមួយភាគីអូស្ត្រាលី ដើម្បីផ្តល់វគ្គបណ្តុះបណ្តាលសមត្ថភាពដល់ មន្ត្រីអនុវត្តច្បាប់កម្ពុជាអំពីជំនាញព័ត៌មានចារកម្ម ។

-បន្តកិច្ចសហការនិងសម្របសម្រួលជាមួយស្ថានទូតសហរដ្ឋអាមេរិក ក្នុងការស្នើសុំឱ្យជួយធានានិរន្តរភាពមន្ទីរពិសោធន៍គ្រឿងញៀនថ្នាក់ជាតិ និងស្នើសុំមន្ទីរពិសោធន៍គ្រឿងញៀនថ្នាក់ភូមិភាគ ។

-សហការនិងសម្របសម្រួល ជាមួយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត ជំរុញឱ្យអាជ្ញាធរនៅមូលដ្ឋាន បន្តយកចិត្តទុកដាក់ធ្វើកិច្ចសន្យារដ្ឋបាលឱ្យបានហ្មឹងម៉ាត់ជាមួយម្ចាស់ផ្ទះសំណាក់ សណ្ឋាគារ ក្លឹបកំសាន្ត និង កន្លែងសប្បាយ នៅក្នុងមូលដ្ឋានរបស់ខ្លួន ។

-រៀបចំបើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីអនុវត្តច្បាប់ លើការងារប្រយុទ្ធប្រឆាំងគ្រឿងញៀននៅខេត្តបាត់ដំបង និងប៉ៃលិន(ក្រោមការជួយឧបត្ថម្ភគាំទ្រដោយគំរោងទ្វេភាគី កម្ពុជា-កូរ៉េ) ។

## ៤_កិច្ចសហប្រតិបត្តិការអន្តរជាតិ

-សហការជាមួយ UNODC ដើម្បីរៀបចំពិធីប្រគល់-ទទួលសម្ភារៈបរិក្ខារការិយាល័យទំនាក់ទំនងព្រំដែន និងធ្វើបញ្ជីសារពើភ័ណ្ឌ ។

-ត្រៀមទទួលក្រុមប្រតិភូបច្ចេកទេសវៀតណាម ដែលត្រូវមកកម្ពុជាដើម្បីពិនិត្យមើលទីតាំងសាងសង់មជ្ឈមណ្ឌលជាតិព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។

-ត្រៀមរៀបចំដំណើរទស្សនកិច្ច ជូនឯកឧត្តមឧបនាយករដ្ឋមន្ត្រីអញ្ជើញទៅប្រទេសវៀតណាម ។

-ត្រៀមរៀបចំដំណើរទស្សនកិច្ចជូនឯកឧត្តមឧបនាយករដ្ឋមន្ត្រី អញ្ជើញទៅសាធារណរដ្ឋប្រជាមានិតចិន ។

## ៥_នីតិកម្ម :

បន្តកិច្ចសហការនិងសម្របសម្រួលជាមួយក្រសួងយុត្តិធម៌ ដើម្បីជំរុញការកែសំរួលសេចក្តីព្រាងច្បាប់ ស្តីពីការត្រួតពិនិត្យគ្រឿងញៀនឱ្យចប់ជាស្ថាពរ ។

ដើម្បីអនុវត្តបានសំរេចនូវផែនការសកម្មភាពអនុវត្តទិសដៅត្រួតពិនិត្យគ្រឿងញៀនខាងលើ  អាជ្ញាធរជាតិនឹងបន្តជំរុញការអនុវត្តន៍គោលការណ៍ប្រៀបសមរភូមិប្រឆាំងបទល្មើសគ្រឿងញៀន ក្នុងនោះសំខាន់គឺ :

-ជំរុញការធ្វើបច្ចុប្បន្នភាពទិន្នន័យព័ត៌មានគ្រឿងញៀន តាមគោលការណ៍ប្រៀបសមរភូមិប្រឆាំងបទល្មើសគ្រឿងញៀន។

-ការអនុវត្តន៍ផែនការប្រតិបត្តិគំរូ នៅខេត្តបន្ទាយមានជ័យ ។

-ជំរុញការរៀបចំសាលារៀនពណ៌បៃតងគំរូនៅវិទ្យាល័យឥន្រ្ទទេវី  ដើម្បីអនុវត្តគោលការណ៍ **ពីរមិន បីត្រូវ** និងវិធានការ ១៥ យ៉ាង ដោយបង្កើតជាយន្តការសំរាប់អនុវត្តនិងតាមដានវាយតម្លៃការអនុវត្តន៍កម្មវិធីសាលាគំរូគ្មានគ្រឿងញៀន ។

-ការពង្រឹងរចនាសម្ព័ន្ធនិងសមត្ថភាពរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

**អគ្គលេខាធិការ**

**<u>ចំលងជូន</u> :**

-ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

-ខុទ្ទកាល័យ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អជបគញ

-ឯកឧត្តម កៅ ខុនដារ៉ា អនុប្រធាន អជបគញ

(ដើម្បីជូនជ្រាប)

-ក្រសួងសមាជិក អ.ជ.ប.គ.ញ

-គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត

-នាយកដ្ឋានសរុប ទីស្តីការគណៈរដ្ឋមន្ត្រី

(ដើម្បីមុខការ)

-ឯកសារ-កាលប្បវត្តិ